Tome III  Roeung Makpayong Kew  R-625-11-52

ម-៤៩៩.១១៣

# រឿង ម៉ាកប៉ាយ៉ុងកែវ

ភាគ៣ តជិតចប់

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL



តម្លៃ ៩រ០០

ឈ្មោះសៀវភៅដែលមានផាវនៅបណ្ណាគារ

## ជឹង ជួន ហួត

គឺ :

| | | | |
|---|---|---|---|
| ១– | ប្រស្នាវិនយបញ្ញត្តិ ទី ១ | ថ្លៃ | ៧រ០០ |
| ២– | បណាមគាថា | ,, | ២រ០០ |
| ៣– | អវិជ្ជាកថា | ,, | ២៤រ០០ |
| ៤– | ភេសជ្ជក្ខន្ទក: ទី ៦ | ,, | ២០រ០០ |
| ៥– | ប្រជុំពុទ្ធភាសិត ៤០០ បទ | ,, | ៨រ០០ |
| ៦– | បុគ្គលកថា | ,, | ៥រ០០ |
| ៧– | សន្ទនាត្រៃភាសា | ,, | ១៥រ០០ |
| ៨– | សន្និសិទ សមាគមមិត្តសាលាបាលី | ,, | ៥រ០០ |
| ៩– | ឃរាវាសធម៌ និង ច្បាប់ទូន្មានកូនចៅ | ,, | ៥រ០០ |
| ១០– | សំវេគកថា | ,, | ៤រ៥០ |
| ១១– | សុភាសិតសង្គ្រោះ | ,, | ១៦រ០០ |
| ១២– | ពុទ្ធប្រវត្តិពាក្យកាព្យ | ,, | ១៧រ០០ |
| ១៣– | សុន្ទរកថា | ,, | ៦រ០០ |
| ១៤– | បញ្ហាសង្គម | ,, | ១៤រ០០ |
| ១៥– | ប្រស្នាពុទ្ធសាសនា | ,, | ៨រ០០ |
| ១៦– | ព្រះបាទជយវរ្ម័ន ទី ៧ | ,, | ៥រ០០ |

ARCHIVES NATIONALES
REGIE DU DEPOT LEGAL
B. 126. 1548
8°

# រឿងម៉ាកប៉ាយុងកែវ ទី ៣

ឥសីថាអើឯងធ្វើហើយ　ខ្ញសញានៅឡើយចារិះរេ
ឯងចូរប្រយ័ត្នក្នុងកាយេ　តាំងសិស្សតាំងមេប្រុងស្មារតី ៗ
ឥសីតាំងមន្តវិជ្ជាការ　រៀនបេះអស្ចារ្យឫទ្ធីល្បី
កាលទ្រង់អង្គុយនៅក្នុំបី　បានបេះបាឡីស្រូបយកខ្យល់ ៗ
តាំងក្បាមផ្សាយមន្តវិជ្ជាការ　ផ្សាយដូចប្រាថ្នាចំពោះដល់
សប្តំធាយាឥតមានខ្យល់　ដកដង្ហើមខ្វល់សូន្យជីវី ៗ
ស្លាប់តាំងអស់គ្នានៅក្នុងព្រៃ　ដោយសីល្បឥសីព្រះភូមី
ស្លាប់ពួកសប្តំនៅក្នុងទី　សូន្យជន្មជីវីអនាថា ៗ
ស្លាប់តាំងកូនសិស្សទាំងលោកគ្រូ　មិនមានសល់យូរក្នុងរុក្ខា
ឥសីឃើញហើយទើបប្រាប់ថា　នៃអើចៅតាទាំងបីប្រាណ ៗ
តាជួយចៅឯងបានស្បើយទុក្ខ　ថ្ងៃក្រោយថ្ងៃមុខចាំស្មោះស្មាន
រូបនាយដាំនេះណាកល្យាណ　គ្នារស់ស្លាប់បានបីដងពិត ៗ
រស់បានបីដង ស្លាប់បីដង　រូបសូន្យជាម្តងមិនរិះគិត
ស្លាប់បានបីដងរស់បីពិត　ចូរពៅវរមិត្រចាំឲ្យជាក់ ៗ
តាផ្តាំបើចៅតាមានទោស　ដោយគ្នាធ្វើខុសទោះអ្នលគាក់
ទោសណាត្រូវជេរគោងនាងអ្នក　សុំធំឲ្យជាក់កុំធ្វើស្តី ៗ
ទោសណាត្រូវវាយឬត្រូវចង　គ្រាន់តែជាផងដោយប្រណី
ទោសណាដល់ស្លាប់វាយទៅខ្ទី　តាផ្តាំទឹងស្រីចៅប្រុសផង ៗ
ឥសីផ្តាំរូបមន្តទៅបាត់　ចាកស្ងាត់នៅតែក្សត្របក្សាស់ប្សង

នាយដាំបុប្ផាស្រស់សុខន នួនល្អឥតប្ដីស្រកល្យាណ ។
ម៉ាកប៉ាយុនកែវត្រេកអរក្រៃ ដឹងនាយដាំទៃយ៉ាងចំណាន
បណ្ដាំលោកតាតាំងពីប៉ុន្មាន អ្នកបាំក្នុងប្រាណមិនភ្លេចសោះ ។
ហើយក៏នាំស្រស់នារីស្រី វិលទៅបុរីដោយស្ម័គ្រស្មោះ
ទៅឯមឿងនៅឯណោះ តោមស្រស់ឲ្យជួបផ្កាស្រី ។
ចេញផុតអំពីព្រៃក្បាទៅ សំដៅចូលទៅក្នុងបុរី
ព្រមតាំងនាយដាំចេញពីព្រៃ ដើរចូលទៅវៃបុនរដ្ឋា ។
ម៉ាកប៉ាយុនកែវដើរចូលទៅ សំដៅប្រាសាទព្រះក្សត្រា
ស្ដេចឆប៉ាឌិនរួចកាលណា បង្គំចេស្ដាដោយគោរព ។
ដល់ហើយបង្គំទូលសេចក្ដី ដល់ព្រះចក្រីយ៉ាងសព្វគ្រប់
លោកក៏ត្រេកអរទឹងស្រស់ម្ញប់ ពីកពនានាខ្វាបតោមយង់ ។
ទ្រង់បាននិតនៅក្នុងមឿងឆ តោមល្អសប្បាយទឹងអណុង្គ
បុប្ផាសុខនស្រីឧត្តុង្គ តោមយង់ស្រឡាញ់នាងផ្កា ។
តាំងពីស្រឡាញ់ស្មើបងប្អូន ដូចកូនផ្ទៃមួយពីមាតា
ស្រឡាញ់គ្នាណាស់ស្មើជីវ៉ា មិនចេញវាចាឲ្យមានហ្មង ។
ដ្បិតនាងតាំងពីដោមហេសី បុប្ផាប្រិមប្រិយ៍នាងជាច្បង
នៅក្នុងមឿងឆនោះឯងហោង សប្បាយកន្ទងក្នុងឋានី ។
នៅដាយូរណាស់ដប់ខែផ្ងាយ សប្បាយតាំងអស់ស្រស់ទេវី
ម៉ាកប៉ាយុនកែវព្រួយក្នុងទី សម្ដីរឹកដល់រាជក្រុងក្រៃ ។

សមយេនា កាលសម័យនោះ ស្ដេចព្រួយចំពោះឥតសង្ស័យ
នឹកទៅមាតាបិតាថ្លៃ បមតែទៅលាស្រីកញ្ញា ។
ទៅដល់ប្រាសាទស្អាតប្រសើរ ទ្រង់ធ្វើដំណើរទៅហើយណា
ដល់ហើយសាសង៍ទៅពីគា ប្រាយប្រាប់កាថាប្អូនស្រី ។
ចូរប្អូននិតនៅទីនោះហើយ ប្អូនអើយបងទៅរាជបុរី
ចាំបងរៀបគោសេះដំរី មកទទួលថ្លៃបានសមល្អ ។
បើយើងវិលចូលទៅទាំងអស់ មិនសមតោមស្រស់ដោយធម៌ស
ចូរពៅនៅសិនស្រស់បវរ បងនឹងវិលមកយកប្អូនទេ ។
នាងថាបើទ្វោះសូមចក្រពង្ស សូមទ្រង់ប្រណីដល់មាសមេ
យកនាយដាំទៅណាតោមស្នេហ៍ កុំឲ្យបែកបែរសោះជាម្ដង ។
សូមយកនាយដាំដាប់តាមទៅ កុំឲ្យទុកនៅក្រែងមានហ្ន
សូមយកនាយដាំឲ្យទៅផង សូមក្សត្របព្រាស់បន្ទ្រង់មេត្តា ។
រួចហើយនាងហៅនាយដាំមក លៃលកសាសព្ទហើយផ្ដាំថា
បើសិនព្រះអង្គដល់សេមា ក្រែងមានពីគាប្រពន្ធថ្មី ។
ចូរកូនអ្នកតែងសំបុត្រមក លៃលកសាសព្ទឲ្យដឹងក្ដី
នាងផ្ដាំរួចហើយកល្យាណី នៅប្រាសាទជ័យសុខសប្បាយ ។
ម៉ាកប៉ាយុនកែវលោកាលណា នាំគ្នាយាត្រាក្សត្រតោមឆាយ
យាន់ដើរជាមួយកូនពណ្ណរាយ នឹងនាយដាំនោះសំដៅទៅ ។
ចេញពីរាលតូចចូលរាលធំ ទ្រង់ចាំមិនមានគិតឈប់នៅ

ប្រឹងប្រែងខំយាងទៅតាមផ្លូវ បានយូរតិចទៅដល់សេមា ៗ
ស្ដេចនាំនាយដាំដើរចូលទៅ សំដៅប្រាសាទព្រះបិតា
បានដូចបំណងប៉ងប្រាថ្នា ទៅដល់កាលណាថ្វាយបង្គំ ៗ
លើកដៃគោរពព្រះមាតា ព្រមទាំងបិតាដោយគួរសម
ស្ដេចក៏ត្រេកអរហើយរៀបចំ ឲ្យស្នមទទួលទាំងប្រុសស្រី ៗ
សួរហេតុសុខទុក្ខគ្រប់ប្រការ ពីបុត្រស្នេហាយ៉ាងប្រិមប្រិយ៍
ម៉ាកប៉ាយុងកែវទូលសេចក្ដី ដោយន័យដូចមានឃ្លាខាងដើម ៗ
ស្ដេចក៏ត្រេកអរមិនមានទុក្ខ បាននៅជាសុខនឹងបុត្រឆ្នើម
ពស្ដ្រងផងសប្បាយក្រៃសំបើម ឆោមឆ្នើមទើបទូលទៅបិតា ៗ
បពិត្រព្រះអង្គខ្ញុំបានកូន សមសួនមានឈ្មោះនាយដាំណា
ជួយខ្ញុំប្រិនលើកក្នុងព្រឹក្សា ឲ្យបានសុខាប្រិនកន្ទង់ ៗ
ព្រះចៅត្រេកអរនឹងបុត្រប្រាប់ ស្ទុះទៅឱនចាប់នាយដាំផង
ញញឹមអង្អែលក្បាលនឹងខ្លួន ស្នេហាណាស់ហោងនឹងនាយដាំ ៗ
សុក័ណបុទ្ធិទ្រង់ចាស់នឹងមហេសី ជរាហើយនៃមកប្រចាំ
ទើបទ្រង់ផ្ទេរពង្សតាមចំណាំ បានបងចាំពីបុរាណមក ៗ
ទ្រង់តាំងរាជបុត្រគ្រងសេមា រក្សាពស្ដ្រផងឆោមពន្ទត
នៅគង់សេមាដោយលៃលក រិះរកជាធំលើផែនដី ៗ
ឱបរាជអង្គអាចគង់សេមា មកគាល់ត្រៀបត្រាព្រះបក្រី
ដ្បិតឲ្យធ្វើស្ដេចពូកែល្បី បក្រីទើបមករៀនសិល្បផង ៗ

អភិសេកធ្វើពេធ៍ពេញនគរ　　ពស្ត្រផង់វីវប្រែបនក្នុង
រៀបពេធ៍ជាផ្លូវឥតមានខ្ចង់　　មានប្រែនណាស់ហោង៍ក្នង៍សេមា ៗ
ខ្លះលេង៍អាប៉ោង៍លេង៍យោគី　　ក្នង៍ពជធានីនៃក្សត្រា
សម្បូណ៌សប្បាយគ្រប់អាត្មា　　សុខាតាំង៍កពផែនភាព ៗ
អភិសេករួចហើយបានស្រេចការ　　ថៃ្ង៍ពីសេនានោះវិញជា
ង៉ារមហាឧបរាជស្រស់ពុំង៉ារ　　មានកូនល្អជាតាំង៍ទ្វេហា ៗ
ឧបរាជទី ១ មានកូនស្រី　　កូនមួយទៀតនៃពីរហើយណា
ថ្ងៃមួយឧបរាជមកគិតថា　　អាត្មាគិតថ្វាយកូនទៅស្តេច ៗ
ទើបហៅអូរីជាកូនស្រី　　ថាហៃប្រឹមប្រិយ៍រូបល្អផ្តាច់
នាង៍មកឪយកទៅថ្វាយស្តេច　　ឲ្យបានសម្រេចពេលនេះទៅ ៗ
អូរីបានស្តាប់ពាក្យបិតា　　ស្លៀកពាក់ហើយណាស្រស់ពាលពៅ
ចរចេញអំពីឋានលំនៅ　　ដើរបណ្តាយទៅចូលបុរី ៗ
ឧបរាជនាំកូនបានចូលដល់　　មិនខ្វល់លើកថ្វាយព្រះបក្រិ
ម៉ាកប៉ាយុង៍កែវមានបារមី　　ស្តេចគ្រង៍ផែនដីរួចកាលណា ៗ
ស្តេចក៏ត្រេកអរមិនមានហ្មង៍　　ព្រោះឃើញនួនល្អង៍ឆើតរូបា
ឈប់ស្ទះត្រង៍ណោះមិនបរបា　　ថៃ្ង៍ពីមហាឧបរាជវិញ ៗ
លោកង៉ារទី ២ ធ្វើមន្ត្រី　　លោកមានបុត្ររូបត្រមិញ
ឈ្មោះនាង៍វ៉ារីពេញស្រឡាញ់　　គិតកាញ់យកទៅថ្វាយរាជា ៗ
ទើបហៅបុត្រីស្រីនួនល្អង៍　　រូបល្អក្នុង៍សមសោភា

ថាហៃរ៉ើកូនកុំអារ មកណោះវិញជាទឹងបិតា ៗ
ឪទិងយកកូនទៅថ្វាយស្តេច ឲ្យបានសម្រេចពេលនេះណា
កូនអើយមកទៅយើងយាត្រា ថាហើយកញ្ញាស្រីរៀបខ្លួន ៗ
នាងលាបទឹកអប់ស្រប់អស់កាយ សក់ស្រីធោមឆាយលាបក្រមួន
មាសនាងយកពាក់ឲ្យពេញខ្លួន ទើបនួនបរចេញតាមឪពុក ៗ
ឧបាដទី ២ សំដៅទៅ លំនៅកដាចង់បានសុខ
ដើម្បីឲ្យរូបផុតបាកទុក្ខ ទំនុកឲ្យបានកូនជាធំ ៗ
លុះដើរទៅដល់ទីប្រាសាទ យ៉ាងស្អាតប្រសើរដ៏ឧត្តុង្គ
ឧបាដទី ១ អង្គុយកង្ក បានប្រុងយកកូនថ្វាយរូបហើយ ៗ
ឧបាដទី ២ បានឃើញជាក់ ទ្រង់ភ្ញាក់ផ្អាក់ថ្លើមផ្អើកន្តើយ
តូបចិត្តខ្លាំងណាស់ពុំមានស្បើយ យកកូនមកហើយមិនទាន់គេ ៗ
ណ្ហើយចុះកុំថ្វាយស្តេចធ្វើអ្វី គង់តែមានថ្ងៃទឹងរិះរេ
អ្នកណាមានបុណ្យធ្វើជាមេ អញផ្ញើរឲ្យកូនទៅគេចុះ ៗ
គិតហើយដឹកដៃកូនមកវិញ មាត់ប្រឹងទន្ទេញថាអញខុស
ដើងដើរដម្រង់ទៅផ្ទះស្នោះ មិនមានស្រណោះប៉ុនធូលី ៗ
ឧបាជបានដល់ទៅគេហា គ្មានព្រួយចិន្តានៅក្នុងទី
សប្បាយនៅផ្ទះទឹងនារី យើងទឹងថ្ងៃពីអង្គក្រស័ត្រ ៗ
ម៉ាកប៉ាយុងកែវស្រស់ប្រិមប្រិយ៍ ទ្រង់ស្តីទៅប្រាប់ដោយថ្ងៃបាត់
ទៅឪពុកក្មេកនោះឯងថ្វាត់ ទ្រង់ហើបហាមាត់ស្តីទៅថា ៗ

បពិត្រឪក្មេកខ្ញុំសូមប្រាប់ សារសព្វពីនាយជាំនេះណា
ដ្បិតត្រូវជាកូនមិនមុសា គេមានចេស្តាបុទ្ធិបារមី ៗ
ខ្ញុំលើកកូនខ្ញុំធ្វើឧបរាជ អគ្គអាចធំជាងគេនោះនៃ
ចុះពីខ្ញុំទៅមានបុត្រថ្លៃ ធំក្រៃលើសជនផងនានា ៗ
ឧបរាជទី ១ បានឮជាក់ ក្តៅចិត្តឥតអាក់ទឹងគណនា
ទើបគិតក្នុងចិត្តព្រួយមហិមា ក្តៅទឹងរកជាកូនប្រសា ៗ
ហេតុម្តេចមកយកអាមនុស្សព្រៃ ឲ្យធ្វើធំក្រៃក្នុងវង្សា
អញខំយកកូនមានរូបា ប្រាថ្នាបង់ធំឲ្យលើសលប់ ៗ
ឥឡូវស្រាប់តែស្តេចលើកគេ ឲ្យធ្វើជាមេត្រួតទាំងគ្រប់
ខ្លួនឯងធ្លាក់ងារឲ្យមានទុក្ខ នាំឲ្យមិនសុខក្នុងសន្តាន ៗ
អញធ្វើរាជការយូរឆ្នាំណាស់ ជាន់ចាស់តាំងពីអគ្គក្សត្រក្សាន្ត
ព្រះវរបិតាក្សត្រកល្យាណ មិនដែលខូចប្រាណយសស័ក្តា ៗ
ឥឡូវស្តេចយកអាមនុស្សព្រៃ មិនដឹងការអ្វីសោះឡើយណា
មកឲ្យធ្វើធំខុសធម្មតា ប្រុះគួរអាត្មាគិតឧបាយ ៗ
ឲ្យអាមនុស្សព្រៃនឹងកូនអញ លសីល្បគ្នាវិញទាំងពីរកាយ
បើខាងណាឈ្នះអញមិនស្តាយ លើកជាឯកាយធំទៅចុះ ៗ
គិតហើយបង្គំទៅបក្រី បពិត្រនរបតីមានកិត្តិយស
ដែលលើកកូនទ្រង់ឲ្យធំនោះ ខ្ញុំហ្នឹងរើរុះគ្រានេះហើយ ៗ
សូមឲ្យនាយជាំនឹងកូនប្រុស លគ្នាមើលចុះព្រះត្រាណត្រើយ

ក្នុងពេលព្រឹកស្អែកនេះឯងហើយ    ឲ្យឃើញគៀកកើយរិទ្ធិចេស្តា ៗ
ម៉ាកប៉ាយុនកែវឆ្លើយទៅវិញ    ថាមានចាស់អ៊ើព្រះបិតា
កូនមួយខ្ញុំបើកទៅតាមការ    ឲ្យប្រាំងនរណាមិនមានខ្លាច ៗ
ឧបាដបានស្តាប់បង្គំវិញ    ទៅផ្ទះហើយនៃយ៉ាងអង្គអាច
ខំដើរដម្រង់ទាំងអំណាច    អង្គអាចបានដល់ទៅផ្ទះស្រេច ៗ
ដល់ហើយហៅកូនប្រុសមកវិញ    ថាហៃគិមរិនរូបល្អផ្ដាប់
ព្រឹកនេះបូរកូនកុំខ្លាចស្តេច    ធ្វើឲ្យអង្គអាចកុំសង្ស័យ ៗ
អញឲ្យកូនឯងចេញទៅប្រាំង    តតាំងកូនស្តេចជាមនុស្សព្រៃ
បើកូនបានឈ្នះសូមកុំភ័យ    នឹងបានធំក្រៃប្រាកដពិត ៗ
គិមរិនស្តាប់ហើយឆ្លើយថាបាទ    យ៉ាងស្អាតឆ្លើយល្អតាមគំនិត
ត្រេកអរខ្លាំងណាស់មិនភ័យភិត    គិតតែចង់ធំឥតមួហ្វាង ៗ
លុះដល់ព្រឹកព្រាងស្រេចកាលណា    គឹមរិនកុមារស្រស់ទួនល្អង
រៀបពលយ៉ាងច្រើនស្រែកគឹកកង    ទាំងបិតាផងក្នុងបន្ទាយ ៗ
រៀបពលរួចស្រេចគ្រប់ប្រការ    កុមារត្រួតត្រាធ្វើជានាយ
ដើរចេញទាំងអស់យ៉ាងពណ្ណរាយ    សំដៅទៅឆ្ងាយចុងបុរី ៗ
រៀបពលជិតជុំធ្វើជារង់    នៅក្នុងទីធ្លានោះឯងវិញ
ពួកពស្ត្របណ្ដាជនប្រុសស្រី    ចាំមើលបារមីគេលគ្នា ៗ
ថ្ងៃងពីនាយដាំចាំក្នុងចិត្ត    ក្រោកពីងងឹតចរលីលា
ខំដើរសំដៅចុងភាគ    ទៅតប្ទាឲ្យបានដឹង ៗ

ដើរទៅឃើញពលគេក្រៃក្រាស់ អ្នកត្រេកអរណាស់មិនមានខឹង
ឲ្យតែបានដល់រាំឆាប់ដឹង សំទឹងគំនិតគិតប៉ុនប៉ង ៗ
នាយដាំដើរទៅចូលក្នុងវាំង អង្គុយនៅទឹងស្តីសាសង
សូមអញ្ជើញចូលមកជាមួង ទឹងលមើលផងឲ្យឃើញដៃ ៗ
គឹមរិនឮហើយស្ទុះចូលក្តាម មិនមានទាក់ទាមគិតសង្ស័យ
ស្ទុះទាត់នាយដាំឲ្យខ្លាំងក្រៃ ប៉ុន្តែត្រូវដីមិនត្រូវស្ទោះ ៗ
នាយដាំគ្រាន់តែលោទៅទាត់ បំមាត់បែកាច់ទៅទាំងស្រស់
ដោយឫទ្ធិពូកែដាក់បំពោះ វិសតែមិនរស់ក្ស័យជីវិត ៗ
គឹមរិនក្រោកឡើងអន់កាយី វិលចូលទៅទីបន្ទាយពិត
ព្រមទាំងសេនាមីរង្គឹត តូបចិត្តខ្លាំងណាស់ក្នុងសន្តាន ៗ
ឧបរាជទី ១ ក៏ខឹងដែរ ព្រួយទឹងមាសស្នេហ៍កូនកល្យាណ
តឫទ្ធិចាញ់គេដោយស្មោះស្មាន ក្តៅញ័រអស់ប្រាណក្រៃមហិមា ៗ
នាំពលចូលទៅក្នុងបន្ទាយ មិនមាននិយាយរឿងនានា
ចាំតែរកកលធ្វើខុក្ខរ៉ា ថ្ងៃក្រោយទៅជាប្រាកដហើយ ៗ
ឧបរាជចូលទៅគិតក្នុងផ្ទះ ព្រួយចិត្តខ្លាំងណាស់ពុំមានស្បើយ
ព្រមទាំងគឹមរិនកូនជាត្រើយ ចាំធ្វើកលហើយឲ្យដឹងការ ៗ
ប្រឹងធ្វើឧបាយរកសម្លាប់ ឲ្យនាយដាំស្លាប់ដូចប្រាថ្នា
ឈប់ស្ទុះត្រង់ណោះមិនបរបារ ថ្ងៃងពីមហាឧបរាជនៃ ៗ
លោកអ៊ំរទី ២ ក្នុងសេមា ឃើញនាយដាំណាមានជោគជ័យ

ត្រេកអរក្នុងចិត្តពន់ពេកក្រៃ ទើបគិតកៃខៃធ្វើអាហារ ៗ
ទិញជ្រូកមាន់ទាយកមកកាប់ សម្លាប់យកសាច់ហើយទិញស្រា
ជប់លៀងពួកជនផ្ទះអាត្មា ទើបតែងអក្ខរាមួយយ៉ាងថ្មី ៗ
ឲ្យទៅអញ្ជើញនាយដាំនោះ ថាមកចំពោះដោយមេត្រី
ស៊ីលៀងក្នុងផ្ទះមានសេរី នឹងជូនកូនស្រីឈ្មោះវារ៊ី ៗ
រៀបគ្រឿងអីវ៉ាន់ទុកប្រចាំ ទើបផ្តាំឲ្យហៅទៅសេនីយ
ឲ្យនាំសំបុត្រជូននាយថ្មី នាយដាំនោះនៃឲ្យដឹងការ ៗ
ចូរឯងយកសំបុត្រនេះទៅ ឲ្យដល់លំនៅនាយដាំណា
នៅក្បែរប្រាសាទព្រះចេស្តា បានហើយយាត្រាមកវិញឆាប់ ៗ
សេនីយ៍ឮហើយខំរត់ស្ទៅ សំដៅទៅផ្ទះយ៉ាងប្រញាប់
ដល់ប្រាង្គប្រាសាទបានស្រេចស្រាប់ បានឆាប់ទៅដល់នាយដាំហើយ ៗ
ឃើញនៅក្នុងផ្ទះពេញយ៉ាងស្អាត ប្រាសាទស្តុកស្តម្ភក្យត្រែត្រាណត្រើយ
សេនីយ៍អ្នកដើរចូលដល់ហើយ គៀកកើយគោរពជូនអក្ខរា ៗ
នាយដាំបានចាប់សំបុត្រមក លៃលកលាមើលឲ្យដឹងការ
ដាក់ក្នុងសំបុត្រនោះឯងថា ងាររមហាឧបភជទី ២ ដាក់ ៗ
សូមមកអញ្ជើញលោកនាយដាំ ឲ្យទៅខ្ញុំចាំដោយស្មោះស្ម័គ្រ
អញ្ជើញពិសាចំណីដាក់ ទ្រង់អញ្ជើញអ្នកទៅជាម្តង ៗ
នឹងទៅពិសាអស់ចំណី កុំព្រួយពីអ្វីក្រែងមានហ្ង
ខ្ញុំបង់ស្គាល់លោកពេកកន្ទង សូមទៅលេងម្តងកុំសង្ស័យ ៗ

នាយដាំបានមើលសំបុត្ររួច    កាន់គួបក្នុងចិត្តត្រេកអរក្រៃ
ទុកសំបុត្រហើយដើរចុះខ្ទី    ចេញពីផ្ទះវៃចរលីលា ៗ
សំដៅដើរទៅដោយគំនិត    គន់គិតក្រែងមានហេតុនានា
ឈានដើរតម្រង់តាមផ្លូវផ្កា    មិនមានរេរាឈប់បង្អង់ ៗ
នាយដាំបានដើរសំដៅទៅ    តែម្នាក់ឯងក្បូរដោយស្ម័គ្រស្មោះ
ឧបាសកទី ២ បានឃើញយស់    ក្រោកឈរបំពោះគំនាប់វី ៗ
ហើយសូមនាយដាំឡើងលើផ្ទះ    អង្គុយត្របះនៅចំទី
ឧបាសកស្រែកហៅនាងនារី    ឲ្យមកសម្តីបំរើគេ ៗ
នាងនាថពីរនោមស្រស់ស្រី    ចេញខ្ញីនាងគិតដោយគ្នាន់គ្នេ
ចេញមកបំរើមិនទំនេ    លើកទ្វេហត្ថាជូននាយដាំ ៗ
នាយដាំស៊ីផឹកសប្បាយចិត្ត    មិនព្រួយរិះគិតពីទុក្ខអ្វី
ស៊ីផឹកសប្បាយឃើញកាយស្រី    មិនកើតទោសអ្វីពីត្រង់ណា ៗ
ឧបាសកទី ២ ឃើញនាយដាំ    អង្គុយប្រចាំបរិភោគ្គា
ទើបលោកដើរទៅស្តីចរចា    គំនាប់ប្រាប់ថានៃព្រះគុណ ៗ
ខ្ញុំបានឃើញលោកមានចេតនា    ត្រេកអរអស្ចារ្យមិនសឹយស៊ុន
ខ្ញុំអរគុណលោកទុកជាមុន    រិះគន់ខ្ញុំគិតលើកកូនស្រី ៗ
សូមជូនទៅលោកធ្វើភរិយា    ព្រោះលោកមានចារជាមន្ត្រី
ហើយត្រូវជាកូនធម៌បក្រី    ខ្ញុំជូនកូនស្រីគិតយ៉ាងណា ៗ
នាយដាំបានឮគេឲ្យកូន    ត្រេកអរឥតសូន្យក្នុងកាយា

ទើបឲ្យគិនាប់ស្ដីប្រាប់ថា  ខ្ញុំអរអស្ចារ្យហើយព្រះគុណ ៗ
ដោយទ្រង់ករុណាតដល់រូបខ្ញុំ  ឲ្យនាងក្រមុំស្រស់ល្ហាសល្ហន់
ខ្ញុំក៏ទទួលអរជាមុន  មិនឲ្យសឹយស៊ុនកុំសង្ស័យ ៗ
នាយដាំបានមានគូសង្សារ  ទឹងនាងវ៉ារូបល្អក្រៃ
មានចិត្តត្រេកអរឥតឧបមេយ្យ  បាននាងស្រីថ្លៃធ្វើភរិយា ៗ
នាយដាំបង្គំឪពុកខ្មី  ហើយនាំប្អូនស្រីបរលីលា
ដើរចេញទាំងពីរស្រីពុំឆា  វិលចូលទៅនាគេហដ្ឋាន ៗ
នាយដាំបានអែបនារីស្រី  ស្រឡាញ់ឥតអ្វីនឹងប្រៀបបាន
រួមរ័ក្ខកាយកង្ទីបាន  ស្មោះស្មានស្នេហាតាមប្រឹមប្រិយ៍ ៗ
ដោយហេតុនាយដាំមិនធ្លាប់បាន  រូបស្រីកល្យាណសោះឡើយនៃ
តើបពះពេលនេះបានបោ្មនថ្មី  ស្នេហាប្អូនស្រីប្រាកដពិត ៗ
ទាំងពីរស្នេហាប្ដូរខ្លួនប្រាណ  ស្នេហាក្នុងឋានប្ដូរជីវិត
មិនកើតទុក្ខាព្រួយភ័យគិត  វរមិត្រត្រេកអរមិនមានហ្មង ៗ
ឈប់ស្លុះត្រង់នេះមិនចែងស្ដី  ថ្ងៃពីសេទីយ៍នោះវិញម្ដង
ឧបភដទី ១ នោះឯងហោង  ក្ដៅចិត្តកន្ទង់ទឹងនាយដាំ ៗ
ដោយហេតុទាត់កូនជិតដល់ក្ស័យ  ក្ដៅចិត្តពេកក្រៃនៅចង់ចាំ
មួហ្មងក្នុងចិត្តដោយចំណាំ  ហៅកូនមកផ្ដាំប្រាប់ឧបាយ ៗ
ជានៃតឹមរិនមាសឪពុក  ចូលមាសទ្រលុកអ្នកមកអាយ
កូនអើយឪក្ដៅពីរូបកាយ  ឪពុំសប្បាយរឿងទាំងនោះ ៗ

នាយដាំហានទាត់រូបកូនឯង  រាំធ្វើឥតក្រែងក្នុងពេលនោះ
គោងគាបព្រៃហ៊ុនគ្មានក្រែងសោះ  ហៃកូនកំឡោះស្ដាប់បិតា ៗ
កូនឯងសំលៀងកាំបិតទៅ  ឲ្យបានមុតស្រួចដូចប្រាថ្នា
ដុនឹងឲ្យពេលរៀបអាហារ  អញ្ជើញសេនានាយដាំខ្វី ៗ
ឲ្យមកស៊ីផឹកក្នុងបន្ទាយ  ចាក់ស្រាចាំងឡាយកុំស្ដាយអ្វី
ឲ្យតែនាយដាំក្រេបស្វារតី  កូនចាក់ទៅខ្វីណាតាមងាយ ៗ
សម្លាប់នាយដាំមួយពោលទៅ  កូនពៅយើងនៅតែពីរកាយ
បានចំប្រាកដណាតាមងាយ  យើងនឹងសប្បាយទៅខាងមុខ ៗ
គឺមិនបានស្ដាប់ពាក្យបិតា  ត្រេកអរអស្ចារ្យមិនមានទុក្ខ
ដោយមើលទៅឆ្ងាយថាបានសុខ  ញញឹមស្រស់មុខពេលនោះនៃ ៗ
ឧបាជ្ឈទី ១ រៀបអាហារ  មានគ្រប់ប្រការមុខទីទៃ
ស្រាក៏ទិញច្រើនមកក្រាស់ក្រៃ  បម្រុងសំច័យប្រចាំការ ៗ
រួចហើយទើបប្រើទាហានម្នាក់  ឲ្យជួយកក់ទាក់នាំយកសារ
ជូនទៅនាយដាំជាសេនា  នៅក្នុងរដ្ឋាប្រាកដហើយ ៗ
ទាហានឮនាយស្ដីប្រើខ្លួន  ត្រេកអរម៉ាំមួនមិនមានស្បើយ
ផ្លូវជិតមិនមែនផ្លូវឆ្ងាយឡើយ  ពុំមានគោះតើយដើរចូលទៅ ៗ
ទើបយកសំបុត្រជូននាយដាំ  ហុចតាមចំណាំគេប្រើទៅ
នាយដាំត្រេកអរយ៉ាងត្រឹមត្រូវ  តាមឆ្មៅអ្នកចាប់អានសំបុត្រ ៗ
ដឹងជាក់សេចក្ដីក្នុងត្រានោះ  ត្រេកអរបំពោះពិតប្រាកដ

ទើបហៅប្អូនស្រីវីរ័ត៌ | កំណត់ឲ្យមកប្រាប់កិច្ចការ ៗ
វីរពុទ្ធីហៅនួនល្អ | ត្រេកអរកន្ទ្រំវរកនិដ្ឋា
នាងមកអង្គុយជិតសន្ធារ | ចាំស្តាប់កិច្ចការប្តីប្រាយប្រាប់ ៗ
នាយដាំថាហៃកែវពីសី | ប្អូនស្រីមាសបងនាងចាំស្តាប់
ឧបកដទី ១ គេប្រញាប់ | ឲ្យបងទៅឆាប់សុំចំណាំ ៗ
ហេតុនេះបាប្អូននាងនៅចុះ | ឆោមស្រស់ស្តាប់បងណានួនស្រី.
ពាលពៅនៅចុះកុំទៅអី | តាមតែប្អូនប្តីចុះមាសស្ងួន ៗ
នាងនាថដាំថាទែអ្នកបង | ពេលនេះឯងហោងប្រយ័ត្នខ្លួន
ក្រែងកើតមានភ័យយ៉ាងម៉ាំមួន | ជួនជាមានទុក្ខមកដល់ប្រាណ ៗ
នាយដាំបានស្តាប់ពាក្យប្អូនស្រី | ដើរចុះទៅទឹកងទីបាន
វ៉ារតាមមើលប្តីកល្យាណ | នាងឃើញសោះសានប្តីគានក ៗ
ដាប់បាត់ឃើញតែខ្លួនទទេ | មាសមេស្មុះទៅឧបអង្ករ
អ្នកបងកុំទៅឃើញមិនល្អ | ខ្ញុំឃើញដាច់កកុំទៅអី ៗ
អាណិតមកចិត្តដល់ប្អូនម្ត | អ្នកបងសូមជឿពាក្យប្អូនស្រី
បងឯងតែទៅចុះរាសី | ខ្ញុំសូមចិត្តប្តីគ្រានេះម្ត ៗ
នាយដាំឆ្លើយថាហៃប្អូនស្រី | នាងកុំឃាត់អីណានួនល្អ
ប្អូនកុំព្រួយស្តាប់ពីរឿងបង | កុំភ័យឡើយហោងណាឆោមឆាយ ៗ
ថាហើយនាយដាំដើរទៅទៀត | ខំធៀតដើរទៅតែឯកាយ
មិនព្រួយអ្វីសោះឆោមពណ្ណរាយ | ដើរទៅពីនាយបានដល់ហើយ ៗ

ឧបាសកទី ១ ក្រោកទទួល បបួលឲ្យឡើងលើផ្ទះហើយ
ចាក់ស្រាជូនដល់នាយដាំហើយ នាយដាំពុំស្បើយត្រេកអរក្រៃ ៗ
ស៊ីផឹកសប្បាយពេញតែផ្ទះ សប្បាយខ្លាំងណាស់ឥតសង្ស័យ
ប៉ុន្តែនាយដាំប្រយ័ត្នក្រៃ កែវ១ផឹកហើយធ្វើដួលប្រាណ ៗ
គឺមិនស្ទុះយកកាំបិតភ្លាម ចាក់មិនទីមទាមដល់អង្គកាយ
នាយដាំឃើញហើយគេចប្រវាយ បែរទៅទាត់ខ្ចាយសូន្យជីវិត ៗ
ទាត់ត្រូវគឺមិនស្លាប់តែម្តង គ្មានរស់ឡើយហោងប្រាកដពិត
បែកឈាមក្នុងផ្ទះជាប់នៅនិត្យ នាយដាំដើរគិតបរយាត្រា ៗ
មកដល់ផ្ទះហើយមិនចេញស្តី ប្រពន្ធសួរអ្វីអ្នកមិនថា
មុខក្រៀមទ្រូងក្រំដាំឧរា នាងសួរយ៉ាងណាអ្នកមិនប្រាប់ ៗ
រ៉ារីនាងសួរអង្វរប្តី យំក្រៃនាងឧនសួរសារសព្ទ
នាយដាំមិនស្តីជាដ៏កប់ មិនមានប្រាយប្រាប់ទៅសោះឡើយ ៗ
ថ្ងៃងពីឧបាសកទី ១ វិញ ជាទុក្ខទោមនេញយំពុំស្បើយ
ថាឧផលកម្មមកដល់ហើយ កូនអើយគឺពៀរយើងទេណា ៗ
មន្ត្រីលើកកូនពារចេញទៅ សំដៅចូលវាំងកូនប្រសា
លុះចូលទៅដល់ទីប្រាង្គប្រា ដល់ស្តេចហើយណាព្រះឆោមឆាយ ៗ
ឧបាសកចូលទៅថ្វាយបង្គំ លើកដៃប្រណម្យពីចម្ងាយ
ស្តីហើយបង្អុលមករូបកាយ ដល់រូបឆោមឆាយកូងពីសី ៗ
បពិត្រព្រះអង្គមានបេស្តា នាយដាំមោហាចិត្តអប្រិយ៍

ខ្ញុំយល់ថាខ្លួនមន្ត្រីថ្មី មកពីក្នុងព្រៃកើតព្រួយប្រាណ ៗ
ខ្ញុំធ្វើចំណីគ្រប់ប្រការ ហើយខ្ញុំឲ្យសារធាប់ចំណាន
អញ្ជើញនាយដាំទៅកំសាន្ត ដើម្បីឲ្យបានបរិភោក្តា ៗ
បានទៅស៊ីផឹកក្នុងផ្ទះហើយ ស្រវឹងគ្មានស្បើយស្រែកឡូឡា
ដើរចុះដើរឡើងទាត់បុត្រា ឲ្យសូន្យជីវ៉ាជីវិតក្ស័យ ៗ
ហេតុនេះសូមទ្រង់ជួយពិគ្រោះ អំពីរឿងនោះព្រះបមត្រៃ
ហេតុម្ដេចចិត្តធំក្លាខ្លាំងក្រៃ មកកាយកូនខ្ញុំសូន្យជីវី ៗ
ម៉ាកប៉ាយុងកៃវត្សជូព្រោះ ក្តៅញ័រពុងពោះនៅក្នុងទី
ទើបហៅអាមាត្យដោយសម្តី ឲ្យរត់ទៅរីហៅនាយដាំ ៗ
អាមាត្យខំរត់មិនមានឈប់ ដល់ហើយគោរពតាមចំណាំ
ថាព្រះក្សត្រាហៅប្រចាំ ឲ្យខំរត់មកអញ្ជើញលោក ៗ
នាយដាំឆ្លើយថាទៅមុនចុះ អាមាត្យត្រូវព្រោះមិនរំលោក
ខំរត់ទៅទូលព្រះទ្រង់ជោគ ឲ្យលោកបានជ្រាបគ្រប់វគ្គឃ្លា ៗ
នាយដាំអ្នកគិតពីផ្ទះទៅ អញនឹងសំដៅដល់រាជា
អញមិនពោលទេព្រោះឥតគ្នា រាជាសួរម្ដេចអញមិនស្តី ៗ
បើអញនិយាយតករាជា ឥតគ្នាសាសងជាសាក្សី
ណ្ហើយចុះបើស្លាប់ស៊ូដេកដី ស្លាប់ទៅក៏ល្បីជួយក្សត្រា ៗ
គិតហើយចុះដើរពីផ្ទះខ្មី ដើម្បីបង្គំព្រះបិតា
ដល់ហើយលំទោនទូនសិរសា អាគ្មាឧទ្ធាបរាបប្រក្រតី ៗ

ម៉ាកប៉ាយុនកែវឃើញនាយដាំ  សួរមិនបាច់ចាំគិតពីអ្វី
ថាអើនាយដាំកូនប្រិមប្រិយ៍  ហេតុអ្វីអ្នកទៅកាត់គេស្លាប់ ៗ
ចូរកូនស្តីមកកុំមុសា  ប្រាយប្រាប់បិតាឲ្យដឹងឆាប់
កូនឯងមានទោសធំចំណាប់  ឪពុកបើកច្បាប់លែងអ្នកបាន ៗ
នាយដាំមិនស្តីអង្គុយធ្មឹង  ស្តេចខឹងញាប់ញ័រអស់អង្គប្រាណ
ថានែនាយដាំកូនកល្យាណ  កុំស្មានបិតាមិនអាណិត ៗ
កូនឯងឪសួរអ្នកប្រាយប្រាប់  ឲ្យឪពុកស្តាប់បានអស់ចិត្ត
ចូរកូនសារសងណាវរមិត្រ  រិះគិតឲ្យល្អកុំសង្ស័យ ៗ
ស្តេចសួរប្រាំហាលពីរម៉ោងផ្កាយ  បែកញើសចេញខ្ចាយព្រះចមត្រៃ
ក្តៅណាស់បង្អុរនាយដាំវៃ —  ថាហៃអាក្អើកុំធ្វើក្អាត់ ៗ
អញធ្វើឪពុកអាប៉ុនក្នុំ  អញសូមសួរអាហើយមិនមាត់
អានេះព្រហើនចោរចិត្តក្បត់  កំណាត់ទាត់កូនបិតាអញ ៗ
គឺមិនគ្នាស្លាប់ដោយសារអា  ជាប្អូនប្រសាពេញសំឡាញ់
អាឯងចិត្តធំនាំឲ្យគ្នាញ់  មុខអញសួរអាមិនសារសង ៗ
អាស្មានជាអញកូនក្មេងទេ  សួរអាឡើងទ្វេបួនដប់ដង
អាអង្គុយធ្មឹងមិនសារសង  ម្តងនេះហើយអានឹងក្សិណក្ស័យ ៗ
ស្តេចហៅពេជ្ឈឃាតឲ្យចាប់ចង  បណ្តើរចេញផ្គងពីក្រុងក្រៃ
នាយដាំសុខចិត្តដើរហើយនៃ  ដោយក្តីមិនឆ្លើយថ្វាយបមពង្ស ៗ
ពេជ្ឈឃាតបណ្តើរចូលព្រៃក្បា  ដោយប៉ងប្រាថ្នាពិឃាតអង្គ

មិនមានមេត្តាព្រះនោមយន៍ ដល់ហើយពេជ្ឈឃាតស្រែកប្រាប់ថា ៗ
ហៃនៃលោកនាយស័ក្តិយ៉ាន់ខ្ពស់ ពេលនេះមានគ្រោះដល់កាយា
ខ្ញុំក៏មិនដឹងកលកិច្ចការ សូមទានមេត្តាត្រាប្រណី ៗ
បើខ្ញុំសម្លាប់ទៅកាលណា កើតជាតិនានាគ្រប់ជាតិ
កុំឲ្យមានពៀរពេលខែថ្ងៃ ថាហើយកាប់វៃដោយដាវទៅ ៗ
ពេជ្ឈឃាតសម្លាប់មិនស្លាប់សោះ កាប់ប្រិនតែខុសប្រាកដនៅ
មិនមុតនាយដាំប៉ុនស្លឹកស្មៅ ចង់ស្រែករកឪលែងចង់កាប់ ៗ
នាយដាំឃើញគេកាប់ប្រិនដង មិនត្រូវអ្នកផងស្រស់បំណាប់
ហានៃបង់នាយអ្នកចាំស្លាប់ ខ្ញុំប្រាប់សារសង់ឲ្យដឹងដាន ៗ
ចូលយកសំបុត្រទៅមឿងឆ ដាំដែននគរយ៉ាន់ចំណាន
បូរឲ្យយកទៅនាងពីរប្រាណ ដែលស្ថិតនៅឋាននគរនោះ ៗ
ពេជ្ឈឃាតឮហើយកាន់សំបុត្រ ខំរត់ទាំងបីអ្នកចំពោះ
ដោយហេតុមេត្តាធម៌អនុគ្រោះ ខំផ្ដោះឲ្យដល់ដូចបំណង ៗ
សេនាខំរត់ជាយូរក្រៃ តាមដោយក្នុងព្រៃច្បាស់ជាមួន
ព្រួយប្រាណខំរត់មុខឥតហ្ង បានចូលទៅផ្គង់ក្នុងបុរី ៗ
ដើរយកសំបុត្រស្ពរកញ្ញា បូជ៉ាសុខនស្រស់ប្រិមប្រិយ៍
ទើបឃើញសេនាឡើងទៅខ្ញី ហុចជូនទៅស្រីនៃអគ្គា ៗ
នាងនាថបានយល់ឃើញសំបុត្រ សូមទោសប្រាកដដល់មាតា
នាយដាំខ្ទុំខ្ញុំកើតទុក្ខា ក្សត្រាលោកយកសម្លាប់ហើយ ៗ

ហេតុនេះសូមឲ្យអ្នកម្តាយទៅ　　អាណិតដល់ពៅកុំព្រងើយ
ណាមួយបិតាក្សត្រត្រាណត្រើយ　　ស្តេចមានទៀតហើយព្រះមហេសី ៗ
នាងនាថបានទតសំបុត្របប់　　ទ្រង់ជ្រុបព្រះភក្ត្រមិនបង់ស្តី
ឆផ្កានាងសួរសព្វសេចក្តី　　បូង៉ាសុខទស្រីឆ្លើយប្រាប់ ៗ
ថានៃប្អូនស្រីស្រស់មាសបង　　បងព្រួយកន្ទួងតោមចំណាប់
ឥឡូវនាយដាំស្តេចសម្លាប់　　យកទៅបង់កាប់កង្ទុរក្ខា ៗ
ហេតុនេះបូរប្អូននាងនៅចុះ　　ស្រីស្រស់រូបល្អដូចអប្សរ
បងនឹងចេញទៅពីសេមា　　សុំទោសក្សត្រាលមើលម្តង ៗ
ហេតុនេះបូរស្រីនាងកុំទៅ　　ចាំបន្តិចកូវណានួនល្អង
ថ្ងៃក្រោយសូមប្អូនទៅតាមបង　　រួចហើយចេញផ្គងមិនយូរយា ៗ
នាងខំដើរណាស់ដោយអាណិត　　ស្រឡាញ់កូនពិតស្រស់ពុំអារ
នាងខំដើរណាស់មិនរេក　　ដល់ចុងភាកកជក្រុងក្រៃ ៗ
នាងខំដើរទៅចូលប្រាសាទ　　យ៉ាងស្អាតប្រសើរមានដំឡៃ
នាងចូលទៅដល់ព្រះស្វាមី　　លើកដៃបង្គំហើយសួរថា ៗ
បពិត្របមកុដតាមចំណាំ　　ទ្រង់ចាប់នាយដាំយកទោសា
នាយដាំមានទោសខុសយ៉ាងណា　　សូមព្រះកស្តាប្រាប់ប្អូនស្រី ៗ
ម៉ាកប៉ាយុងកែវពុធនាងសួរ　　សំនួរយ៉ាងគួរទើបឆ្លើយឲ្យ
នាយដាំរាចាត់កូនមន្ត្រី　　រាគ្មានគិតអ្វីសោះឡើយណា ៗ
បងសូមសួររាតែមួយមាត់　　រាស្ងាត់សំដីមិនបរបា

វាព្រៃហើនណាស់ខុសធម្មតា    បានជាអាត្មាបងក្តៅណាស់ ៗ
បើឲ្យតែវាឆ្លើយមួយមាត់    វាប្រាប់មកថាត់ឲ្យតែច្បាស់
បងលែងទោសវាដាច់ស្រឡះ    នេះម្ចាស់វាមិនស្តីនឹងបង ៗ
បូង៉ាសុខននាងសុំទោស    សូមមានសន្តោសពេលនេះម្តង
សូមទោសនាយដាំបីថ្ងៃផង    ប្អូនប៉ង់សួរហេតុឲ្យដឹងជាន ៗ
ស្តេចក៏បើកឲ្យដោយអាណិត    អាសូរដល់ចិត្តស្រីកល្យាណ
ទើបនាងយាងទៅប្រាសាទបាន    ទ្រង់គន់គ្រេមក្សាន្តនៅទីនោះ ៗ
ពេជ្ឈឃាតទៅនាំនាយដាំហើយ    មកថ្វាយត្រាណាត្រិយស្រីបំពោះ
នាងក៏ឃើញកូនគង់ពេលនោះ    នាងស្ទុះទៅឱបហើយសួរថា ៗ
ហៃកូនមាសម្តាយសាយបារមី    ហេតុអ្វីក៏អ្នកមានទុក្ខា
ចូរប្រាប់មកម្តាយឲ្យឆាប់ពី    កុំឲ្យសង្កាទៅថ្ងៃក្រោយ ៗ
នាយដាំក្រាបទូលព្រះមាតា    ទូលដល់កញ្ញាមិនឲ្យឃ្លាយ
ថាសូមក្រាបទូលតាមបណ្តោយ    មុខក្រោយសូមចាំណាមាតា ៗ
ដ្បិតលោកឧបរាជជាទី ១    ហៅខ្ញុំយ ៗ ឲ្យយាត្រា
ទៅស៊ីចំណីផ្ទះគេណា    ផឹកស្រាសប្បាយគ្មានសៅហ្មង ៗ
បន្តិចគឺមិនកូនលោកនោះ    វាស្ទុះមកចាក់កូនក្រោយខ្នង
កូនក៏ទាត់ទៅស្លាប់តែម្តង    កូនមិនសារសងដោយយល់ដឹង ៗ
ដ្បិតកូនគ្មានគ្នាជាសាក្សី    បើស្តីក៏គេស្អប់ពេកម៉្លឹង
គេមិនជឿកូនទេព្រលឹង    កូនគ្មានទីពឹងគ្នាមួយពីរ ៗ

ឆ្លើយចុះមាតាសូមប្រណី ស្តេចមិនដឹងអីទ្រង់សម្តីរ
កូនជួយប្រើនៃក្រុងគីរី ឥឡូវកូមីក្បួចគុណអស់ ៗ
កូនសុខចិត្តតែអំពីស្លាប់ មិនប្រាប់ដល់ស្តេចព្រះឆោមស្រស់
សូមម្តាយអ្នកជ្រាបកិច្ចទាំងអស់ កូនខុសយ៉ាងណាប្តូរកុំស្តី ៗ
ប៉ូង៉ាសុខនយកកូនសួរ អស់ទាំងសំនួរគ្រប់ថ្ងៃបី
ដល់ពេលកំណត់គ្រប់ហើយនៃ ពេជ្ឈឃាតឡើងខ្ចាប់នាយដាំ ៗ
ចងបណ្តើរទៅកន្លែងចាស់ ដោយចាំផាត់បក្រស់ប្រុងចំណាំ
ហើយឲ្យអង្គុយប្រុងប្រចាំ គ្នា ៤ គាប់រឹមិនស្លាប់ទៀត ៗ
នាយដាំឆ្លើយថាអ្នកកុំកាប់ ខ្លួនខ្ញុំមិនស្លាប់កុំខំធ្វៀត
សូមឲ្យទៅទូលព្រះភវនាថ យ៉ាងយ៉ាតមកគាប់ទើបក្សិណក្ស័យ ៗ
អាមាត្យព្រួហើយរត់ប្រញាប់ បានឆាប់បរចូលរាជក្រុងក្រៃ
ដល់ហើយនូនក្រាលក្រាបលើកដៃ ថាសូមបក្រៃមានបេស្តា ៗ
ទូលបង្គំសម្លាប់នាយដាំនោះ វានៅតែរស់ទេក្សត្រា
បើមកឲ្យទ្រង់កាត់សិរសា ទើបបានដីវាក្សិណក្ស័យ ៗ
ម៉ាកប៉ាយុងកៃវត្ថុថារស់នៅ ទ្រង់យាងចុះទៅទាញខាន់ជ័យ
ទៅតាមពេជ្ឈឃាតមិនមានភ័យ បានចូលក្នុងព្រៃជួបបំណង ៗ
ដល់ហើយនាយដាំញញឹមព្រាយ និយាយឆ្លើយហាក់អរកន្លង
ថាវៃហលោកឪរូបឥតហ្មង កូនជួយប្រើនផងដល់ក្សត្រា ៗ
ពេលនេះខ្លួនកូនកើតមានទោស ឆ្លើយចុះសូមទ្រង់កាត់សិរសា

ស្តេចឮដូច្នោះមិនមេត្តា　　　កាប់សូន្យជីវ៉ានាយជាំទៅ ។
នាយជាំបានកើតជាខ្មោចជាក់　　　ទ្រង់លក្ខណ៍ដែលកាប់ជាប់ទិតនៅ
នាយជាំជាខ្មោចក្នុងព្រៃជ្រៅ　　　តែងទៅរក្សាបុប្ផាស្រី ។
ឆោមយង់សម្លាប់នាយជាំហើយ　　　គ្រាណាត្រើយវិលចូលក្នុងបុរី
នៅសុខសប្បាយគ្មានទុក្ខអ្វី　　　យើងស្ដីឧបាដទី ១ វិញ ។
តូបចិត្តនឹងស្តេចមានមហេសី　　　បុប្ផានោះនៅកើតទុក្ខមេញ
ថ្វាយកូនស្មានថាធំពោរពេញ　　　ឥឡូវតួបវិញជាចុងគេ ។
បើច្នោះយើងគិតទៅទូលក្សត្រ　　　ពីរឿងវិបត្តិស្រស់មាសមេ
ថាយកនាយជាំមកគ្នាទគ្នេ　　　រិះរេសារសងសុទ្ធស្វាមី ។
បុប្ផាសុខនយកនាយជាំ　　　ប្រចាំស្រឡាញ់គ្នាឥតបី
គ្មានបានសាកសួរពីរឿងអ្វី　　　ឮតែហៅប្ដីក្នុងប្រាសាទ ។
គិតហើយលីលាដើរត្របទៅ　　　សំដៅដំណាក់ព្រះឆោមស្អាត
ទៅដល់ក្រាបទូលយ៉ាងដល់ខ្នាត　　　សង្វាតដូចមានខាងដើមឃ្លា ។
ទូលថាបុប្ផាសុខនស្រី　　　យកប្ដីនាយជាំប្រាកដជា
បីថ្ងៃខ្ញុំឃើញដេកឱបគ្នា　　　ទូញយំកុំព្រាឥតសង្ស័យ ។
ម៉ាកប៉ាយុងកែវឮដូច្នោះ　　　ទ្រង់គិតបំពោះពីស្រីថ្ងៃ
កាលនៅរក្សានាងគ្មានប្ដី　　　ព្រាត់អញយូរក្រៃប្រាកដហើយ ។
វាបាននាយជាំយកទៅនៅ　　　ស្រឡាញ់គ្នាគួរនោះមែនហើយ
មេនេះពិតជាបានគ្នាហើយ　　　គ្រាណាត្រើយទ្រង់ហៅនាយសេនីយ៍ ។

បងឯងចូរទៅចាប់ប្អូន សុខនេះណាស្រស់ប្រិមប្រិយ៍
ចាប់យកសម្លាប់កុំប្រណី កុំនាំមកអីក្នុងដំណាក់ ៗ
យកវាសម្លាប់ចោលក្នុងព្រៃ ទុកវាធ្វើអ្វីនាំកើតអាក់
សម្លាប់វាទៅឲ្យដឹងដាក់ ទំលាក់ក្នុងជ្រោះកុំមេត្តា ៗ
សេនីយឮហើយរត់ត្រសង ប្រឹនគ្នាកន្លងដល់កញ្ញា
ចាប់ក្ដាមទះតប់សត្វមំសា នាងមិនដឹងការណ៍ទេស្រស់ស្រី ៗ
ភ័យញ័រអស់កាយសួរប្រញាប់ ថាបងឯងចាប់មានទោសអ្វី
ចូរប្រាប់ឲ្យឆាប់ដល់ខ្លួនស្រី ឬមួយចក្រីប្រាប់យ៉ាងណា ៗ
ពេជ្ឈឃាតឮហើយឆ្លើយទៅវិញ ដ្បិតព្រះចក្រីប្រើខ្ញុំថា
ឲ្យនាំចាប់ចងទៅព្រឹក្សា សម្លាប់ធិតាឥតសង្ស័យ ៗ
លោកគ្មានប្រាប់រឿងដល់ខ្ញុំសោះ ទៅកុំស្រណោះគិតកិតភ័យ
ថាហើយសេនានាំចូលព្រៃ នាងសួរម្ដេចក្ដីមិនសារសង ៗ
នាំដើរទៅដល់ទីឋានស្ងាត់ លើកដាវឡើងថ្វាត់កាប់តែម្ដង
នាយដាំដាវខ្ចាចនៅក្រោយខ្នង បំបាំងនួនល្អងយកទៅបាត់ ៗ
សេនីយកាប់ដីមិនឃើញសោះ កាប់ត្រូវដីសោះដោយប្រយ័ត្ន
ស្រាប់តែព្រះនាងទៅណាបាត់ ក៏ចាត់ឲ្យឯងកើតមានហ្ន ៗ
សេនីយក៏នាំគ្នាយាត្រា ចូលក្នុងសេមាដើរត្រសង
ទ្រង់ទូលទោមឆាយក្សត្រច្បាស់ច្បង ស្ដេចអរកន្លងទឹងមាសស្ងួន ៗ
ត្រេកអរទឹងនាងស្លាប់ទៅហើយ ត្រាណាត្រើយពុំស្បើយឃើញបាត់ខ្លួន

ស្ទេះសិនថ្លែងពីស្រីទំមន្ទួន　យកស្ងួនទៅដាក់លើសាលា ៗ
ដាក់នាងដូចដើមកន្ទ្រង់ចាស់　នាយដាំយល់ច្បាស់ក្នុងចិន្តា
ដាក់នាងឲ្យនៅតាមធម្មតា　ស្ទេះទៀតហើយណាគ្រានេះម្តង ៗ
ថ្លែងពីផ្កានារីស្រី　ព្រលប៊ីជាអគ្គក្សត្រប្រុសច្បង
សម្រាប់ប្អូនស្រីសុខុន　នឹងនាយដាំផងសូន្យជីវិត ៗ
នាងក្តៅក្នុងកាយញ័រអស់ប្រាណ　ក្តៅទ្រង់ក្សត្រក្សាន្តស្តេចមិនគិត
សម្លាប់ព្រះនាងស្រីស់វរមិត្រ　មិនគិតនាយដាំជួយទោសា ៗ
ណ្ហើយចុះអញទុកស្តេចធ្វើអី　ធ្វើប្តីមិនសមក្នុងសេមា
អញក្មេងជាប្រុសឲ្យដឹងការ　សម្លាប់កស្តាចោលទៅចុះ ៗ
គិតហើយស្ទៀកពាក់រូបយ៉ាងសម　ពាក់មួកយ៉ាងហំទៅជាប្រុស
ក្មេងកាយរូបហើយស្រីចរចុះ　កាន់ដាវដាប់ស្មោះទឹងហត្ថា ៗ
ខំរត់ម្នាក់ឯងក្នុងព្រៃកព្រៃ　សំដៅចូលវៃក្នុងរដ្ឋា
បានដូចបំណងនៃកញ្ញា　ស្ទុះធ្វាដើររកប្រាសាទបាន ៗ
នាងស្ទុះឃើញក្ស័ត្រព្រះស្វាមី　ស្រ្តីស្ទុះកាប់ស្តេចកល្យាណ
៖បាកដទី ១ ស្ទុះចាប់បាន　បំណានបងដាប់នារីស្រី ៗ
ដេរថាហឹងឯងចិត្តកោងកាច　កំណាចហ៊ានមកកាប់ចក្រី
ហឹងឯងដឹងទេក្សត្រផែនដី　មុខហឹងនឹងក្ស័យសូន្យជីវិត ៗ
នាងឆ្លើយថាខ្ញុំមិនខ្លាចស្លាប់　បានជាដេញកាប់ព្រះធោមសិទ្ធ
ព្រោះតែសម្លាប់នាយដាំពិត　នឹងវៃកវររមិត្រជាម្ចាស់បង ៗ

ម៉ាកប៉ាយុវកែវបង្អួរក្លាម ហងកុំទាក់ទាមនាំសៅហ្មង
ពេជ្ឈឃាតបូរអានាំទូនល្អង ហើយបង់សម្លាប់កុំមេត្តា ៗ
ពេជ្ឈឃាតភ្ញុះហើយលោតទាត់ប៉ាង នាងអុកក្តិតតាំងបងហាត្ន
នាំក្សេតបរបួលក្នុងរេខ្គា ដាក់នាងជីតាកន្ទេងដើម ៗ
ជាទីសម្លាប់ជាប្រក្រតី ដាក់ស្រីអង្គុយស្រស់មាសផ្ទើម
ពេជ្ឈឃាតសំដាវយ៉ាងសម្បើម ខ្មោចមកដណ្តើមយកទៅទៀត ៗ
នាយដាំបានយកនាងផ្កា ចូលក្នុងព្រៃក្រាំខ្ពស់ទ្រៀត
ឲ្យនៅជាមួយស្រស់នាងនាថ ខ្ទឹឃ្មាតទុកដាក់ក្នុងសាលា ៗ
ថ្ងៃពីពេជ្ឈឃាតយារដាវកាប់ ត្រូវដីព្រុជាប់ខ្លួនដួលដា
អាមួយវាឃើញស្រែកអីយ៉ា អាណាកាប់ដីដូចមុនហើយ ៗ
ពេជ្ឈឃាតទាំងឡាយពេញហៅធ្វល់ ពិផលក្នុងចិត្តពិមានស្បើយ
កាប់ត្រូវតែដីពិតជាត្រើយ ឯងកាប់ទៅហើយត្រូវដីពិត ៗ
ដូច្នេះនាំគ្នាទូលក្សត្រា ថានាងជីតាសូន្យជីវិត
ស្លាប់នៅក្នុងព្រៃស្រស់វិមិត្រ យើងទូលខុសពិភតែដូចត្រូវ ៗ
អាមាត្យចូលទូលវរក្សត្រា តាមពាក្យមុសាគិតតាមផ្លូវ
ស្តេចក៏ត្រេកអរទើងពាលពៅ ស្លាប់ទៅក៏ល្អប្រសើរណាស់ ៗ
ថ្ងៃពីឧបាដលោកទី ២ ជាឪរ៉ាវីប្រាកដច្បាស់
ព្រោះដម្រិតតែកូនស្លាប់ស្រឡះ គឺនាយដាំច្បាស់សូន្យជីវិត ៗ
លោកត្រូវជាឪក្មេកនាយដាំ កើតទុកប្រចាំមកញាំញី

ផ្ចិតកូនចាំងអស់នៅក្នុងទី ខ្លះសូន្យជីវិតក្ស័យ ៗ
បើព្រោះអញហ៊ានរៀបសេនា ប្រុងប្រៀបការយារក្រុងមានភ័យ
ទើបកេណ្ឌសេនាបានច្រើនក្រៃ បង្ហាត់កាលថ្ងៃក្នុងបន្ទាយ ៗ
ដើរគោកដើរទឹកសន្ធឹកក្រៃ ក្រាបលួនពេញផ្ទៃយ៉ាងពណ្ណរាយ
អឹងកងក្រែសកហោពេញបន្ទាយ និយាយឧបរាជទី ១ នោះ ៗ
រាជឹងឧបរាជលោកទី ២ កេណ្ឌពលម៉ឺន ១ ដាក់បំពោះ
គិតឡើងទៅទូលព្រះទ្រង់យស ពីព្រោះគំនិតរាគិតថា ៗ
ពីព្រោះឧបរាជជាទី ២ ខឹងនឹងភូមីអង្គក្សត្រា
ព្រោះផ្ចិតសម្លាប់កូនប្រសារ គិតក្បត់ក្សត្រាយកផែនដី ៗ
គិតហើយឧបរាជទី ១ នោះ ដើរឡើងចំពោះប្រាសាទទ្វី
ដល់ហើយក្រាបទូលទៅចក្រី ដោយនៃសាវសង្ក្រាបទូលថា ៗ
បង្គំថាសូមព្រះអង្គជ្រាប ទូវភាពដំណើរនៃសេនា
ឧបរាជទី ២ ចិត្តហានក្លា នាំពលសេនាប៉ុនក្រុងក្រៃ ៗ
ផ្ចិតរៀបទ័ពច្រើនក្នុងបន្ទាយ ហោសើចសប្បាយតែកាលថ្ងៃ
ហេតុនេះសូមទ្រង់កុំសង្ស័យ ក្រែងលោមានភ័យទៅថ្ងៃមុខ ៗ
ម៉ាក់ប៉ាយុងកែវត្តដូច្នោះ ធោមស្រស់មានភក្ត្រទ្រង់កើតទុក្ខ
ទើបស្ដេចទៅភ្លាមដោយតាលមុខ ថាសូមបមកតរៀបសេនា ៗ
ចូលទៅលោមព័ទ្ធចាប់ឧបរាជ ទី២អង្គអាចចិត្តហានក្លា
ចាប់ហើយសូមកាត់តែសីរសា យកចូលសោមាឲ្យផងដាន ៗ

នាយដាំទាត់ធាក់មិនមេត្តា　ដេរថាអាចោរក្បត់ចមចៅ
អាឯងប៉ុណ្ណេះលែងឃើញនុ　អាផ្ដាំគ្នាទៅវ៉ៃអាស្វា ៗ
ដឹងទេអាមនុស្សក្បត់ផែនដី　មិនរស់យូរនៅក្នុងសេមា
មនុស្សមើលមិនឃើញមានទេវតា　បរាមុខអាឲ្យក្ស័យប្រាណ ៗ
រឿងមុនអាឯងមានកូនប្រុស　ព្រះចៅទ្រង់យសស្រស់កល្យាណ
ឲ្យអញធ្វើធំក្នុងរាជស្ថាន　អាឯងបិត្តហ៊ានហៅកូនមក ៗ
ឲ្យចូលតបុទ្ធិបំពង់ទឹងអញ　អាចាញ់តែទៅគិតលៃលក
ធ្វើកលចាក់អញដោយរិះរក　អញទាត់ពន្ធកអាស្លាប់បាត់ ៗ
ឥឡូវម្ដងនេះអាស្លាប់ហើយ　មិនទុកអាឡើងចៃក្ដាត់
ថាះហើយនាយដាំទាញដាវកាត់　បួនប្រាំកំណាត់តាំងពីរនាក់ ៗ
ស្លាប់នៅក្នុងព្រៃអរសោចកើត　ឥតស្រណោះទេអាអប្បលក្ខ
នាយដាំកាប់ចោលហើយទាត់ធាក់,　ដើរវិលចូលដាក់ក្នុងភាព ៗ
ហើយក៏វិលចូលក្នុងប្រាសាទ　នុបរ័ស្អាតស្រស់ពុំរា
ស្ដេចក៏បានសុខគ្មានវេទនា　សប្បាយមហិមាក្នុងសេមា ៗ
រាស្ត្រនៅក្នុងរដ្ឋទាំងប្រុសស្រី　បានសប្បាយក្រៃទឹងក្សត្រា
មិនមានកើតហ្វូងសោះឡើយណា　នៅក្នុងរដ្ឋាបុរីរម្យ ៗ
អង្ករទឹងស្រូវមានពេញពាស　ពួកក្រស្ដសប្បាយមកជួបជុំ
រីករាយទាំងអស់យ៉ាងសមរម្យ　នៅក្នុងសេមាបុររដ្ឋ ៗ
ថ្ងៃពឹងខ្មោចលោកឧបាជ　ទី១អំណាចដោយអំណាត់

ស្លាប់ទៅជាខ្មោចយ៉ាងប្រាកដ វាកត់ចងពៀរនឹងនាយដាំ ៗ
ខ្មោចដើរមកដល់ផ្ទះវ៉ារី ស្គាល់ច្បាស់នារីដោយចងចាំ
ពិតជាព្រៃពន្ធលោកនាយដាំ វាបានចំណាំជាយូរហើយ ៗ
ទើបវាបញ្ចូលចិត្តស្រស់ស្រី រកចៃឲ្យប្ដីស្រីត្រាណាត្រើយ
ឲ្យនាងរកចៃពុកន្ដើយ រកហើយមុខតែនាយដាំនោះ ៗ
នឹងសូន្យជីវិតពិតប្រាកដ ដ្បិតផ្កាឈូករ័តន៍នៅចំពោះ
លើក្បាលនាយដាំទើបបានរស់ ខ្មោចនោះបញ្ចូលចិត្តស្រីពៅ ៗ
វ៉ារីថ្ងៃនោះនាងអផ្សុក គលិយុគនឹកប្ដីមិនចង់នៅ
ទើបហៅនាយដាំស្រស់ស្រនើ ថាលោកចូលមកខ្ញុំរកចៃ ៗ
នាយដាំទុកក្បាលឲ្យស្រីរក ពេលកស្នេហាឥតសង្ស័យ
នាងហូតផ្កាចេញស្ងួនថាចៃ អំពីក្បាលប្ដីស្រីមាសមេ ៗ
ផ្កាឈូកដែលអគ្គគាត់សី ប្រស់រស់ទៅខ្ទីដោយរិះរេ
ស្រាប់តែនាងដកគ្មានដឹងទេ នាយដាំនោះប្រែរលាយបាត់ ៗ
នាងយំដោយនាងមិនដឹងប្ដី ស្រាប់តែរកប្ដីរូបសូន្យស្ងាត់
បោកកាយតោមឆាយយំពេកក្ដាត់ នាងគិតវិបត្តិក្នុងប្រាសាទ ៗ
ថ្ងៃពីនាយដាំទៅជាខ្មោច គាសោចរូបកាយទៅយ៉ាងស្ងាត់
ថៃរទៅខាងណោះខ្មោចឧបកដ ទី១អង្គ អាចពិតដូចប៉ង ៗ
នាយដាំតតាំងច្បាំងគ្នានី ខ្មោច ៗ តាំងពីរនោះជាមួង
ឧបកដទី១ចំកន្ទុង ត្បាច្បងបួលច្បាំងឥតសង្ស័យ ៗ

លោតឆាក់លោតទាត់ជាមួយគ្នា ខ្ទោចៗដូចគ្នាចំបាំងក្រែក
ផ្អើលពួកយម្ពបាលបាស់ជើងដៃ, ភិតភ័យឃើញគេច្បាំងនឹងគ្នា ៗ
ទើបរត់ទៅទូលលោកយមរាជ ដែលចាំកត់ហេតុរឿងនានា
យម្ពបាលដល់ហើយឱនវន្ទា ក្រាបទូលពណ៌នាថ្លែងសេចក្តី ៗ
បពិត្រព្រះគុណមានខ្មោចមនុស្ស វាឈ្លោះច្បាំងគ្នាត្រង់នោះខ្មី
យមរាជឮហើយជ្រើសសេនីយ ទៅវៃចាប់យកទាំងពីរប្រាណ ៗ
យមរាជសាកសួរពាក្យសេចក្តី នាយដាំឆ្លើយវៃទាំងប៉ុន្មាន
ដូចមានដើមឃ្មាដល់អ្នកអាន ចូរស្តាប់ឲ្យបានរឿងលោកសួរ ៗ
លោកក៏ឃើញទោសនាយដាំនោះ ដួយជាតិចំពោះពិតជាគួរ
ហើយឲ្យទៅកើតមិនជាជួ យ៉ាងគួរកុងផ្លែប្រែពន្ធវិញ ៗ
ឧបរាជទី១ចុះនរក ដេកតែក្ងក់កក់កើតទុក្ខម្នេញ
ជ្រិតខ្លួនក្បត់ជាតិរឹងម្ចះម្ចិញ រឿងនេះត្រង់ព្រេញតាមសត្រា ៗ
ភក្តុមាស-ពុំលោកបណ្ឌិត បានគិតជាយូរហើយលោកចារ
រឿងជូនដល់ជាតិខេមរា មើលតាមបញ្ញាគ្រាន់កំសាន្ត ៗ
ឯវំ ហេតុ សូមបែងចប់ ដោយមិនប្រែសប់យ៉ាងចំណាន
អ្នកប្រាជ្ញកាព្យាឃ្លោងទាំងប៉ុន្មាន បើអានឃើញខុសសូមមេត្តា ៗ
បញ្ចប់សេចក្តីប៉ុណ្ណេះហើយ ឱ! បងប្អូនអើយទុកជាការ
មាស-ពុំបណ្ឌិតបានបែងចារិក ទិដ្ឋកាថាចប់ប៉ុណ្ណឹងហោង ៗ

ចប់រឿងម៉ាកប៉ាយុងកែរតែប៉ុណ្ណោះ

| | | | |
|---|---|---|---|
| ១៧- | រឿងហិបហោះ | ថ្លៃ | ៨រ០០ |
| ១៨- | សរសេរតាមសូត្រ ពន្យល់ | ” | ២០រ០០ |
| ១៩- | ប្រជុំសិក្ខាបទក្នុងបាតិមោក្ខ | ” | ១០រ០០ |
| ២០- | វេយ្យាករណ៍បទីប | ” | — |
| ២១- | ប្រស្នាកថាយនូបត្ថម្ភកៈ ទី ២ | ” | ២០រ០០ |
| ២២- | ច្បាប់វដ្ដធម្មន្ទញ | ” | ១០រ០០ |
| ២៣- | ដ័រណាកថា | ” | ២រ០០ |
| ២៤- | អនុពុទ្ធប្រវត្តិ | ” | ២២រ០០ |
| ២៥- | ទុល្លភធម៌ | ” | ៧រ០០ |
| ២៦- | រឿងម៉ាកប៉ាយុនកែវ ទី ១ – ២ – ៣ | ” | ៩រ០០ |
| ២៧- | អន្តរធានកថា | ” | ១០រ០០ |
| ២៨- | សំយោគវិធាន | ” | ១៣រ០០ |
| ២៩- | ៣ ភាសា ខ្មែរ-ចិន-យួន ទី ១ | ” | |
| ៣០- | រឿងបុទ្ធវង្ស ទី ១ | ” | ៨រ០០ |
| ៣១- | រឿងលិនថោង | ” | |
| ៣២- | រឿងវរនេត្រវរនុជ ទី ១ | ” | ១០រ០០ |
| ៣៣- | រឿងសុវណ្ណហង្ស | ” | |
| ៣៤- | អរិយមគ្គាធិប្បាយ | ” | |

រោងពុម្ព ម៉ង-វ៉ើ
លេ១៨៣ ផ្លូវហេស៊ុញី
ភ្នំពេញ